**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

លេខ ០៦៤ ទសក

ថ្ងៃ អង្គារ ៨ រោច ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០២១

## សេចក្តីណែនាំ

## ស្តីពី

## ការអនុវត្តប្រកាសលេខ ០៨៥ ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១ ស្តីពីការធ្វើបច្ចុប្បន្នភាពវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មរមណីយដ្ឋានទេសចរណ៍

ដើម្បីជួយសម្រួលដល់មូលដ្ឋានអាជីវកម្មទេសចរណ៍ដែលកំពុងដំណើរការក្នុងការចូលរួមបង្ការ ការពារ និងរក្សាបាននូវសុវត្ថិភាព ទំនុកចិត្ត និងផ្តល់ភាពកក់ក្តៅជូនភ្ញៀវទេសចរ ក្រសួងទេសចរណ៍បានប្រកាសឱ្យអនុវត្តនូវ "**វិធានសុវត្ថិភាពទេសចរណ៍**" ចំពោះសេវាកម្មទេសចរណ៍ចំនួន **០៦** កាលពីថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០២០ ក្នុងនោះរួមមាន **"វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មរមណីយដ្ឋានទេសចរណ៍"** ផងដែរ។

ជាលទ្ធផល រមណីយដ្ឋាន និងគោលដៅទេសចរណ៍ទេសចរណ៍នានា បានចាប់ផ្តើមបើកដំណើរឡើងវិញជាបណ្តើរៗ។ ចលនាទេសចរណ៍ផ្ទៃក្នុងទៅកាន់តំបន់រមណីយដ្ឋានទេសចរណ៍នានា បង្កើតបានជាប្រាក់ចំណូលជូនបងប្អូនប្រជាពលរដ្ឋ និងវិស័យឯកជន រួមចំណែកទ្រទ្រង់វិស័យទេសចរណ៍មួយផ្នែក កាត់បន្ថយផលប៉ះពាល់នៃការធ្លាក់ចុះនៃចំនួនភ្ញៀវទេសចរអន្តរជាតិ ពិសេសរួមចំណែកទ្រទ្រង់ដល់ការបន្តសកម្មភាពទេសចរណ៍ និងសេដ្ឋកិច្ចនៅតាមមូលដ្ឋាន។

ទន្ទឹមនឹងនេះ ស្របពេលដែលរាជរដ្ឋាភិបាល បាននិងកំពុងអនុវត្តយ៉ាងសកម្មនូវយុទ្ធនាការជាតិចាក់វ៉ាក់សាំងកូវីដ-១៩ និងជំរុញផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋទាំងអស់ប្រកាន់ខ្ជាប់ឱ្យបានខ្ជាប់ខ្ជួននូវវិធានការ **"៣ ការពារ និង ៣កុំ"** ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ក្នុងសហគមន៍ ក្រសួងទេសចរណ៍បានធ្វើបច្ចុប្បន្នភាពលក្ខខណ្ឌនៃការអនុវត្តមួយចំនួនឆ្លើយតបទៅនឹងគន្លងប្រក្រតីភាពថ្មី និងស្ថានភាពនាពេលបច្ចុប្បន្ន។

ក្នុងន័យនេះ ក្រសួងទេសចរណ៍ សូមធ្វើការណែនាំដល់ម្ចាស់ និងអ្នកគ្រប់គ្រងអាជីវកម្មរមណីយដ្ឋានទេសចរណ៍ទាំងអស់ ត្រូវបន្តយកចិត្តទុកដាក់រៀបចំការអនុវត្តឱ្យបានម៉ឺងម៉ាត់នូវខ្លឹមសារប្រកាសលេខ ០៨៥ ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១ ស្តីពីការធ្វើបច្ចុប្បន្នភាពវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មរមណីយដ្ឋានទេសចរណ៍ ដូចខាងក្រោម៖

**១.** ត្រូវរៀបចំផែនការកែតម្រូវសម្បទាអាជីវកម្មរបស់ខ្លួនឱ្យស្របនឹងលក្ខខណ្ឌតម្រូវ និងចំណុចណែនាំទាំងឡាយដូចមានកំណត់ក្នុងខ្លឹមសារប្រកាសលេខ ០៨៥ ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១។ អាជីវកម្មត្រូវចាត់ទុកលក្ខខណ្ឌទាំងនោះជាគោលការណ៍ចម្បងសម្រាប់ការអនុវត្តក្នុងដំណាក់កាលនេះ និងត្រូវអនុវត្តឱ្យបានហ្មត់ចត់ និងដោយស្មារតីទទួលខុសត្រូវ

២. ត្រូវមានស្មារតីភ្ញាក់រលឹក គិតគូរអំពីបញ្ហាសុវត្ថិភាពភ្ញៀវ សុវត្ថិភាពបុគ្គលិក និងសុវត្ថិភាពសង្គមជាតិជាអាទិភាពចំពោះមុខ។ អាជីវកម្មត្រូវហ៊ានលះបង់ធនធាន កម្លាំង និងពេលវេលា ដើម្បីត្រៀមលក្ខណសម្បត្តិឱ្យបានសមស្របនឹងលក្ខខណ្ឌតម្រូវ មុននឹងសម្រេចចិត្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។ ទន្ទឹមនឹងនេះ ត្រូវខិតខំជំរុញការគ្រប់គ្រង និងអភិវឌ្ឍរមណីយដ្ឋានទេសចរណ៍ក្នុងបរិបទ **"គន្លងប្រក្រតីភាពថ្មី"**

៣. ត្រូវពង្រឹងការគ្រប់គ្រងរមណីយដ្ឋានទេសចរណ៍ឲ្យបានល្អប្រសើរ ពិសេសត្រូវកំណត់ **សមត្ថភាពផ្ទុក** (Carrying Capacity) អតិបរមា ដែលអាចទទួលភ្ញៀវបានក្នុងពេលតែមួយ អនុលោមតាមស្តង់ដាគម្លាតសុវត្ថិភាព និងមិនត្រូវទទួលភ្ញៀវលើសពីចំណុះនេះជាដាច់ខាត

៤. ត្រូវអនុវត្តឲ្យបានយ៉ាងខ្ជាប់ខ្ជួន និងម៉ឺងម៉ាត់នូវវិធានការទាំងឡាយដែលបានដាក់ចេញ ដោយក្រសួងសុខាភិបាល និងវិធានសុវត្ថិភាពទេសចរណ៍របស់ក្រសួងទេសចរណ៍ ក្នុងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ពិសេស**វិធានការ "៣ការពារ និង ៣កុំ"** និងត្រូវរៀបចំឱ្យមានការបណ្តុះបណ្តាលបុគ្គលិករបស់ខ្លួនអំពីវិធានការខាងលើឲ្យបានជាប្រចាំ

៥. ត្រូវចូលរួមផ្សព្វផ្សាយរាល់វិធានការនានាដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នមានសមត្ថកិច្ច សំដៅបង្ការ និងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩

៦. ត្រូវអនុវត្ត និងប្រើប្រាស់ឱ្យបានត្រឹមត្រូវនូវគ្រប់ប្រព័ន្ធបច្ចេកវិទ្យាដែលបានដាក់ឱ្យអនុវត្ត ដោយរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ ពិសេសការស្កេន QR Code ទប់ស្កាត់កូវីដ-១៩

៧. ជម្រុញការចូលរួមរបស់រមណីយដ្ឋានទេសចរណ៍ជាមួយរាជរដ្ឋាភិបាលក្នុងការអនុវត្តនូវគោលនយោបាយនានាក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ពិសេសគាំទ្រដល់គោលនយោបាយចាក់វ៉ាក់សាំងរបស់រាជរដ្ឋាភិបាល តាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្រ និងសកម្មភាពជាក់ស្តែង។

ទទួលបានសេចក្តីណែនាំនេះ សូម រដ្ឋបាលរាជធានី ខេត្ត និងម្ចាស់អាជីវកម្មរមណីយដ្ឋានទេសចរណ៍ ត្រូវចូលរួម និងជំរុញការអនុវត្ត សំដៅទប់ស្កាត់ឱ្យបានការរីករាលដាលជំងឺកូវីដ-១៩នៅក្នុងសហគមន៍។

រដ្ឋមន្ត្រី

ថោង ខុន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- គណៈកម្មាធិការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
- សាលារាជធានី ខេត្ត
- មន្ទីរទេសចរណ៍រាជធានី ខេត្ត
- គ្រប់អាជីវកម្មទេសចរណ៍ និងគោលដៅទេសចរណ៍ទូទាំងប្រទេស
- ឯកសារ កាលប្បវត្តិ